# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jun-2012, 13:06
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ និងឧបសម្ពន្ធសម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ : **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ

ការពិនិត្យឡើងវិញចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យទទួលយកចម្លើយសាក្សីពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន នៅដំណាក់កាលទី ១

---

<u>ដាក់ដោយ៖</u>

**សហព្រះរាជអាជ្ញា**

ជា លាង

Andrew CAYLEY

<u>ផ្ញើជូន៖</u>

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រមJean-Marc LAVERGNE

ចៅក្រម យូ ឧត្តរា

<u>ចម្លងជូន៖</u>

**ជនជាប់ចោទ**

នួន ជា

អៀង សារី

ខៀវ សំផន

**មេធាវីការពារក្ដី**

សុន អរុណ

Michiel PESTMAN

| | |
|---|---|
| **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី** | Victor KOPPE |
| **ពេជ អង្គ** | **អាង ឧត្តម** |
| Elisabeth SIMONNEAU FORT | Michael G. KARNAVAS |
| | **គង់ សំអុន** |
| | Anta GUISSÉ |
| | Arthur VERCKEN |
| | Jacques VERGÈS |

## I. សេចក្ដីផ្ដើម

1. កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់សេចក្ដីសន្និដ្ឋានរបស់ខ្លួន ដោយអនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង (សំណើ)[1]។ ក្នុងសំណើរបស់ខ្លួន សហព្រះរាជអាជ្ញាបានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងប្រកាសថា ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ ពុំទាក់ទិនទៅនឹងទង្វើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ (ឬបញ្ហាគន្លឹះនានានៅក្នុងសំណុំរឿងនេះឡើយ) អាចត្រូវបានទទួលយក ដោយពុំមានវត្តមានរបស់សាក្សីនៅសវនាការសម្រាប់ការសួរដេញដោល។ សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើនេះ កំពុងស្ថិតក្រោមការពិចារណានៅឡើយ។

2. គោលបំណងនៃសេចក្ដីសន្និដ្ឋាននាពេលបច្ចុប្បន្ននេះ គឺដើម្បីកំណត់អត្តសញ្ញាណចម្លើយជាលាយលក្ខណ៍អក្សរជាក់លាក់មួយចំនួន ទាក់ទិននឹងដំណាក់កាលទី១ និងដំណាក់កាលទី២ នៃការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ដែលនៅក្នុងសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា សមស្របសម្រាប់ឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកជាភ័ស្តុតាង។ ក្នុងការធ្វើដូច្នេះ សហព្រះរាជអាជ្ញាមានគោលបំណងជួយដល់អង្គជំនុំជម្រះសាលាដំបូង ក្នុងការចេញសេចក្ដីសម្រេចមួយលើសំណើមុននេះ និងក្នុងការរៀបចំសម្រាប់កិច្ចដំណើរការនីតិវិធីនៅដំណាក់កាលបន្ទាប់។

3. សំណើនេះមានឧបសម្ព័ន្ធចំនួន ៥ អមមកជាមួយ។ **ឧបសម្ព័ន្ធ I និង II** មានសម្រង់នៃរបាយការណ៍ជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សីរបស់សហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") ("ចម្លើយសាក្សី") ដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលទៅនឹងដំណាក់កាលទី១ នៃការផ្លាស់ទីលំនៅប្រជាជន ដូចដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។ សម្រង់ទាំងនេះមានភ័ស្តុតាងបញ្ជាក់សំខាន់ៗ ពាក់ព័ន្ធនឹងការបញ្ជាក់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានចោទប្រកាន់មកលើជនជាប់ចោទ នៅក្នុងសវនាការដំណាក់កាលដំបូង ក្នុងសំណុំរឿង០០២ ដែលមានជាអាទិ៍គឺ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មនុស្សឃាត ការសម្លាប់ផ្ដាច់ពូជ ការធ្វើទុក្ខបុកម្នេញខាងនយោបាយ

---

[1] សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ (សំណើ) ឯកសារ E96។

និងអំពើអមនុស្សធម៌ដទៃទៀត តាមរយៈការជម្លៀសដោយបង្ខំ[2]។ ពិសេស សម្រង់ទាំងនេះចង្អុលបង្ហាញអំពីលក្ខណៈជាទ្រង់ទ្រាយធំអចិន្ត្រៃយ៍ និងមានលក្ខណៈចាប់បង្ខំនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ ស្ថានភាពអមនុស្សធម៌ដែលមនុស្សត្រូវបានជម្លៀស បានទទួលរងក្នុងអំឡុងពេលនៃការជម្លៀស និងអំឡុងពេលនៃការមកដល់ ការរើសអើង និងការកាប់សម្លាប់ "ប្រជាជនថ្មី" និងអតីតទាហាន និងអ្នករដ្ឋការ លន់ នល់ ក្នុងអំឡុងពេលនៃការជម្លៀស និងអំឡុងពេលនៃការមកដល់។ លើសពីនេះទៀត សម្រង់ទាំងនេះផ្តល់ភ័ស្តុតាង អំពីការជម្លៀសប្រជាជនពីទីប្រជុំជន និងភូមិផ្សេងៗទូទាំងកម្ពុជា នៅមុនពេល ឬក្នុងពេលដំណាលគ្នាជាមួយការជម្លៀសប្រជាជនទីក្រុងភ្នំពេញ។ ត្រង់នេះជួយបញ្ជាក់ថា ពុំមានមូលដ្ឋានគតិយុត្តិណាមួយ សម្រាប់ការជម្លៀសប្រជាជនទីក្រុងភ្នំពេញឡើយ ហើយតាមការពិត ការជម្លៀសប្រជាជននៅតំបន់ទីប្រជុំជន គឺជាផ្នែកសំខាន់មួយនៃគោលការណ៍សហកម្មខក្រិដ្ឋកម្មរួម ដែលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានបង្កើតឡើង និងបានអនុវត្ត។

4. **ឧបសម្ព័ន្ធ** III ផ្តល់សេចក្តីសង្ខេបមួយក្នុងទម្រង់ជាតារាង អំពីសម្រង់ចម្លើយសាក្សីដែលមាននៅក្នុង **ឧបសម្ព័ន្ធ** I និង II។ តារាងនេះដាក់បញ្ចូលនូវទីតាំងដែលមនុស្សត្រូវបានជម្លៀសទៅ ឬទីតាំងដែលមនុស្សត្រូវបានជម្លៀសចេញ ដោយយោងទៅតាមចម្លើយសាក្សី លេខនៃចម្លើយដែលបញ្ជាក់អំពីការជម្លៀសទៅកាន់ទីតាំងណាមួយ ឬចេញពីទីតាំងណាមួយ និងសេចក្តីលម្អិតនៃចម្លើយទាំងនោះ។ **ឧបសម្ព័ន្ធ** IV មានបញ្ជីមួយនៃចម្លើយសាក្សីទាំងអស់ដែលត្រូវបានដាក់បញ្ចូល តាមលំដាប់អក្ខរាវិរុទ្ធនៃឈ្មោះរបស់សាក្សី។ **ឧបសម្ព័ន្ធ** V មានដាក់បញ្ចូលផែនទីចំនួន ២ ដែលបង្ហាញអំពីទីតាំងដែលមនុស្សត្រូវបានជម្លៀសចេញ ឬទីតាំងដែលមនុស្សត្រូវបានជម្លៀសទៅ ដោយយោងទៅតាមចម្លើយសាក្សីទាំងនេះ។

5. សហព្រះរាជអាជ្ញាស្នើថា ចម្លើយទាំងអស់របស់សាក្សីដូចបង្ហាញក្នុង**ឧបសម្ព័ន្ធ** I និង II ដែលមានភ្ជាប់មកជាមួយនឹងសំណើនេះគួរត្រូវបានទទួលយកជាភ័ស្តុតាង និងដាក់លេខ E3 ត្រង់ផ្នែកណាដែលមិនទាន់ត្រូវបានទទួលយកជាភ័ស្តុតាង។ សហព្រះរាជអាជ្ញាស្នើទៀតថាសម្រង់នៃចម្លើយសាក្សី ដែលបានដាក់បញ្ចូលក្នុង**ឧបសម្ព័ន្ធ** I និង**ឧបសម្ព័ន្ធ** II គួរត្រូវបានអង្គជំនុំជម្រះសាលាដំបូងលើកយកមកធ្វើជាសំអាង ក្នុងប្រភេទភ័ស្តុតាងត្រួត ដើម្បីគាំទ្រដល់សក្ខីកម្មផ្ទាល់មាត់ ដែលត្រូវបានស្តាប់នៅសវនាការ

[2] មើលឧបសម្ព័ន្ធភ្ជាប់នឹងសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ឯកសារ E124/7.1 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ត្រង់ទំព័រទីពីរ ចំណុចទី៤។

ក្នុងការកំណត់អំពីបទចោទប្រកាន់ទាំងឡាយ មកលើជនជាប់ចោទក្នុងសវនាការដំណាក់កាលដំបូងនៃសំណុំរឿង០០២នេះ។ ជាចុងក្រោយ សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា នាពេលឆាប់ៗខាងមុខខ្លួននឹងដាក់សំណើទី២ ដោយមានភ្ជាប់មកជាមួយនូវសម្រង់នៃចម្លើយសាក្សីដែលពាក់ព័ន្ធនឹងការជម្លៀសប្រជាជននៅដំណាក់កាលទី២ ដូចដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។

## II. សេចក្តីសង្ខេបនៃសម្រង់ចម្លើយសាក្សីនៅក្នុងឧបសម្ព័ន្ធ I និង II

6. សម្រង់ចម្លើយសាក្សីដែលមាននៅក្នុង**ឧបសម្ព័ន្ធ I** និង **II** ត្រូវបានដកចេញមកពីកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលបានធ្វើឡើងដោយ ក.ស.ច.ស ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ។ ដូចដែលបានកត់សម្គាល់នៅក្នុងសំណើរបស់សហព្រះរាជអាជ្ញាកាលពីលើកមុន ចម្លើយទាំងនេះមានតម្លៃជាភស្តុតាងយ៉ាងច្បាស់ក្រឡែត និងមានសូចនាករបង្ហាញអំពីភាពជឿទុកចិត្តបានយ៉ាងច្បាស់លាស់ ដែលត្រូវបានធ្វើឡើងដោយមានសម្បថ បានកត់ត្រាដោយមន្ត្រីតុលាការ បានចុះហត្ថលេខា និង/ឬ ផ្តិតមេដៃដោយសាក្សី អមមកជាមួយនូវខ្សែអាត់សំឡេង និងមានបោះត្រាផ្លូវការរបស់ ក.ស.ច.ស[3]។

7. **ឧបសម្ព័ន្ធ I** និង **II** ពុំមានបញ្ចូលសម្រង់នៃចម្លើយផ្សេងៗទៀតពីសាក្សីដែលធ្វើឡើងដោយតតិយជន (ដូចជា DC-Cam ឬ SOAS) ពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬពីបណ្តឹងដែលបានដាក់ជូនមក អ.វ.ត.ក ឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ វាមានសារៈសំខាន់ណាស់ក្នុងការកត់សម្គាល់ថាចម្លើយទាំងនេះ ដែលមាននៅក្នុងសំណុំរឿង ផ្តល់នូវប្រភពដ៏មានតម្លៃមួយនៃសក្ខីកម្មបន្ថែម ទាក់ទិននឹងការជម្លៀសប្រជាជន។ សហព្រះរាជអាជ្ញារំពឹងថា ខ្លួននឹងដាក់ជូនសម្រង់ដែលដកចេញពីចម្លើយផ្សេងៗទៀតទាំងនេះ នៅដំណាក់កាលក្រោយទៀតនៃកិច្ចដំណើរការនីតិវិធី ដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការពិចារណា។

8. **ឧបសម្ព័ន្ធ I** និង **II** ពុំមានបញ្ចូលសម្រង់នៃចម្លើយរបស់សាក្សី ដែលបានផ្តល់សក្ខីកម្មដោយផ្ទាល់មាត់រួចហើយ ឬដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់អត្តសញ្ញាណថាជាសាក្សីសំខាន់សម្រាប់ ការបែងចែកការជំនុំជម្រះក្តីពីដំបូងឡើយ[4]។ ទាក់ទិននឹងបញ្ហានេះ សហព្រះរាជអាជ្ញាកត់សម្គាល់ ការ

---

[3] សំណើ, កំណត់សម្គាល់ទីមួយខាងលើ ត្រង់កថាខណ្ឌ ៣៨ ឯកសារ E96 ។

[4] ដូចមានការបញ្ជាក់នៅក្នុងឧបសម្ព័ន្ធសម្ងាត់ ក ៖ ផ្នែកមួយនៃបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សវនាការដំណាក់កាលដំបូងនៃសំណុំរឿង ០០២ ឯកសារ E131/1.1 ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ និងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលា

សម្រេចពីមុនរបស់អង្គជំនុំជម្រះសាលាដំបូងថា នៅពេលសាក្សីធ្វើសក្ខីកម្ម ការធ្វើសក្ខីកម្មពីមុនទាំងអស់របស់សាក្សីត្រូវបានចាត់បញ្ចូលជាភ័ស្តុតាង[5]។ សហព្រះរាជអាជ្ញាកត់សម្គាល់បន្ថែមទៀតថា ចម្លើយជាច្រើនដែលមាននៅក្នុង**ឧបសម្ព័ន្ធ** I និង II ត្រូវបានផ្តល់ជូនដោយសាក្សី ដែលសហព្រះរាជអាជ្ញាបានស្នើឲ្យកោះហៅនៅពេលសវនាការ[6]។ សហព្រះរាជអាជ្ញារក្សារសិទ្ធិរបស់ខ្លួនក្នុងការដាក់សេចក្តីសន្និដ្ឋានទាក់ទិននឹងសាក្សីទាំងនេះ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងសម្រេចអំពីបញ្ជីឈ្មោះសាក្សីសម្រាប់ដំណាក់កាលក្រោយៗទៀតនៃសវនាការ។

9. ទាក់ទិនទៅនឹងសម្រង់នីមួយៗ **ឧបសម្ពន្ធ** I និង II បញ្ជាក់អំពីជីវប្រវត្តិលម្អិតរបស់សាក្សី (រួមមានឈ្មោះ រហស្សនាមរបស់សាក្សី ប្រសិនបើមាន ភេទ ថ្ងៃខែឆ្នាំកំណើត ឬអាយុ និងតួនាទី នៅក្នុងអំឡុងពេលដែលពាក់ព័ន្ធ) លេខសំណុំរឿង និងលេខE3 ប្រសិនបើមាន នៃចម្លើយសាក្សីដែលសម្រង់នោះត្រូវបានដកចេញ ព័ត៌មានលម្អិតនៃការជម្លៀស រួមទាំងកាលបរិច្ឆេទ និងទីកន្លែងជម្លៀសចេញ និងទីកន្លែងជម្លៀសទៅ ប្រសិនបើដឹង និងចុងក្រោយគឺលេខ ERN នៃសម្រង់ដែលពាក់ព័ន្ធជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង។ ទាក់ទិននឹងទីកន្លែងចេញដំណើរ និងទីកន្លែងទៅដល់ សាក្សីមួយចំនួនពិពណ៌នាអំពីការធ្វើដំណើរឆ្លងកាត់ ឬស្នាក់នៅជាបណ្តោះអាសន្ននៅទីកន្លែងផ្សេងៗគ្នាមួយចំនួន។ នៅក្នុងករណីបែបនេះ ឧបសម្ព័ន្ធបញ្ជាក់តែអំពីគោលដៅចុងក្រោយនៃការជម្លៀស ឬទីកន្លែងដែលអ្នកជម្លៀសបានរស់នៅយូរប៉ុណ្ណោះ។ លើសពីនេះទៀត នៅពេលដែលសាក្សីផ្តល់ឲ្យតែឈ្មោះភូមិ ឃុំ ឬស្រុក ដែលសាក្សីត្រូវបានគេជម្លៀសចេញ ឬជម្លៀសទៅនោះ ប្រភពឯករាជ្យត្រូវបានគេប្រើ ដើម្បីកំណត់អំពីទីកន្លែងពិតប្រាកដរបស់ភូមិ ឃុំ ឬស្រុកនោះ។

---

ដំបូងដែលមានកម្មវត្ថុថា "សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញក្រុមបន្ទាប់ ដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១" ឯកសារ E172 ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១២។

[5] ប្រតិចារឹក, ឯកសារ E1/57.1 ចុះថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២ ត្រង់ទំព័រ ៨៩ បន្ទាត់ ២៤ ដល់ទំព័រ ៩០ បន្ទាត់ ១០។

[6] មើលបញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៨៩ រួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១, ទី២, ទី៣, ទី៣ក, ទី៤ និងទី៥, ឯកសារ E9/4 ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១។ បញ្ជីនេះមានឈ្មោះសាក្សីចំនួន ៥៩ នាក់ ដូចជា TCCP-1, TCW-43, TCW-63, TCCP-6, TCW-91, TCW-114, TCCP-25, TCW-155, TCW-160, TCW-162, TCCP-36, TCW-239, TCCP-40, TCW-252, TCW-253, TCW-257, TCW-263, TCCP-45, TCW-298, TCW-302, TCW-322, TCCP-53, TCW-324, TCW-347, TCW-356, TCW-362, TCW-373, TCCP-64, TCW-380, TCW-386, TCW-412, TCW-422, TCW-426, TCCP-88, TCW-452, TCW-486, TCW-505, TCW-506, TCW-507, TCW-546, TCW-597, TCW-614, TCCP-138, TCW-644, TCW-651, TCW-666, TCW-677, TCW-689, TCW-690, TCW-699, TCW-709, TCW-718, TCW-732, TCW-743, TCW-750, TCW-751, TCW-752, TCW-760, TCW-764, TCCP-169, TCW-789

10. សម្រង់នៅក្នុង **ឧបសម្ព័ន្ធ** I និង**ឧបសម្ព័ន្ធ** II ដកស្រង់ចេញមកពីចម្លើយសាក្សីមួយចំនួនដែលមានភ័ស្តុតាងទាក់ទងនឹងអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទម្នាក់ ឬច្រើននាក់ក្នុងចំណោមជនជាប់ចោទទាំងឡាយ។ ទោះជាយ៉ាងណាក៏ដោយ គួរសង្កត់ធ្ងន់ថា ភ័ស្តុតាងនេះទោះតាមវិធីណាក៏ដោយ មិនទាក់ទងនឹងការដឹង ឬការចូលរួមរបស់ជនជាប់ចោទ ចំពោះការផ្លាស់ទីលំនៅរបស់ប្រជាជននោះទេ។ ជាងនេះទៀត ជាការរក្សាជំហររបស់សហព្រះរាជអាជ្ញាដែលបានថ្លែងរួចមកហើយ[7] ប្រសិនបើសាក្សីទាំងនោះអាចមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះបាន សហព្រះរាជអាជ្ញាមិនស្វែងរកការពឹងផ្អែកលើចម្លើយជាលាយលក្ខណ៍អក្សរដែលផ្តល់ភ័ស្តុតាងសំខាន់នៃអំពើ និងការចូលរួមរបស់ជនជាប់ចោទនៅក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ នៅក្នុងការជំនុំជម្រះដំណាក់កាលទីមួយនៃសំណុំរឿង០០២នោះទេ។

### ក. សម្រង់នានាដែលត្រូវបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ I

11. **ឧបសម្ព័ន្ធ** I មានសម្រង់ចម្លើយរបស់សាក្សីចំនួន ១១៤ នាក់។ ក្នុងនោះ សាក្សីចំនួន ៨ នាក់ ដែលម្នាក់ៗបានផ្តល់ចម្លើយចំនួន ២ ដែលមានន័យថា**ឧបសម្ព័ន្ធ** I មានសម្រង់នៃចម្លើយសរុបចំនួន ១២២។ ទោះជាបែបនេះក្តី ចម្លើយទាំងនេះត្រូវបានរាប់ថាជាចម្លើយតែមួយសម្រាប់គោលបំណងនាពេលបច្ចុប្បន្ន ដោយហេតុថា ចម្លើយចំនួន ២ របស់សាក្សីម្នាក់ៗនេះ លើកឡើងអំពីហេតុការណ៍ដូចគ្នា។ ចម្លើយសាក្សីចំនួន ១៤ ដែលត្រូវបានដាក់បញ្ចូលក្នុង**ឧបសម្ព័ន្ធ** I នេះ ធ្លាប់ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងបានដាក់លេខ E3 រួចហើយ[8]។ ចម្លើយទាំងប៉ុន្មាននៅក្នុង**ឧបសម្ព័ន្ធ** I ទាក់ទិនដោយផ្ទាល់ទៅនឹងការជម្លៀសប្រជាជននៅដំណាក់កាលទី ១ ដូចមានរៀបរាប់ក្នុងកថាខណ្ឌ២២១ ដល់កថាខណ្ឌ២៦០ នៃដីកាដំណោះស្រាយ។ សាក្សីទាំងនេះរួមមានអ្នកដែលត្រូវបានជម្លៀសពីភ្នំពេញ មនុស្សនៅតាមតំបន់

---

7 កំណត់សម្គាល់ទីមួយខាងលើ ត្រង់កថាខណ្ឌ ៣៦ ឯកសារ E96។

8 ឯកសារ E3/69 (D91/12); E3/414 (D233/3); E3/416 (D233/6); E3/436 (D278/4); E3/419 (D234/19); E3/509 (D166/73); E3/369 (D125/31); E3/470 (D94/2); E3/376 (D166/72); E3/427 (D234/7); E3/471 (D94/3); E3/468 (D94/15); E3/546 (D91/7); E3/464 (D92/8). កំណត់ហេតុនៃការស្តាប់ចម្លើយមួយក្នុងចំណោមកំណត់នៃការស្តាប់ចម្លើយសាក្សីទាំងនេះ គឺឯកសារ E3/69 (D91/12) ត្រូវបានទទួលយក នៅថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១១។ មើលបញ្ជីឈ្មោះឯកសារដែលភ្ជាប់មកជាមួយនឹងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ឯកសារ E1/16.2 ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០១១ និងថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១១។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលនៅសល់ចំនួន ១៣ ទៀតត្រូវបានទទួលយក នៅថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២។ មើលឧបសម្ព័ន្ធ ក ដែលភ្ជាប់នឹងសេចក្តីសម្រេចលើការបដិសេធឯកសារនានាដែលត្រូវបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឯកសារ E185.1 ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២។

ជនបទដែលបានឃើញការមកដល់នៃប្រជាជនដែលត្រូវបានជម្លៀសពីភ្នំពេញ និងយុទ្ធជនខ្មែរក្រហម ដែលបានឃើញ ឬបានចូលរួមក្នុងការជម្លៀសនេះ។

12. ចម្លើយចំនួន ៨២ បញ្ជាក់ពីទីតាំងដែលគេជម្លៀសមនុស្សទៅកាន់។ ទីតាំងទាំងនេះមានបង្ហាញនៅក្នុងតារាងខាងក្រោម ដោយភ្ជាប់មកជាមួយនូវកំណត់ហេតុមួយចំនួនដែលបញ្ជាក់ពីការបញ្ជូនមនុស្សទៅកាន់ទីតាំងនោះ ឬមកពីទីតាំងនោះ។ កំណត់ហេតុលម្អិតដែលពាក់ព័ន្ធ រួមបញ្ចូលទាំងលេខឯកសារ និងឈ្មោះសាក្សី មានបង្ហាញនៅក្នុង**ឧបសម្ព័ន្ធ III** ភ្ជាប់នឹងសំណើនេះ។ ព័ត៌មានដែលមាននៅក្នុងតារាងខាងក្រោមនេះ ក៏មានបង្ហាញនៅលើផែនទីទីមួយក្នុង**ឧបសម្ព័ន្ធ V** ផងដែរ។ កំណត់ហេតុដែលនៅសល់ចំនួន ២៧ ផ្សេងទៀត នៅក្នុង**ឧបសម្ព័ន្ធ I** សំដៅជាទូទៅលើការជម្លៀសចេញពីទីក្រុងភ្នំពេញ ដោយមិនមានបង្ហាញពីទីកន្លែងដែលបញ្ជូនអ្នកត្រូវបានជម្លៀសទៅកាន់នោះទេ។ សេចក្តីលម្អិតនៃកំណត់ហេតុទាំងនេះ រួមមានលេខឯកសារ និងឈ្មោះសាក្សី មានបង្ហាញនៅក្នុង**ឧបសម្ព័ន្ធ III**។

| ខេត្ត (ជម្លៀសទៅ) | ចំនួនសម្រង់ |
|---|---|
| បាត់ដំបង | 6 |
| កំពង់ចាម | 5 |
| កំពង់ឆ្នាំង (ភាគច្រើនទៅកាន់ស្រុកសាមគ្គីមានជ័យ) | 13 |
| កំពង់ស្ពឺ | 1 |
| កំពង់ធំ | 3 |
| កំពត | 4 |
| កណ្តាល | 18 |
| កោះកុង | 1 |
| ព្រៃវែង | 8 |
| ពោធិ៍សាត់ | 5 |
| ស្វាយរៀង | 4 |
| តាកែវ (ភាគច្រើនទៅកាន់ស្រុកត្រាំកក់) | 12 |

| | |
|---|---|
| ឧត្តរមានជ័យ | 1 |
| ភូមិភាគបូព៌ា (តំបន់ពិតប្រាកដមិនបានបញ្ជាក់) | 1 |

13. មានការកត់សម្គាល់ឃើញថា ចម្លើយសាក្សីចំនួន១២ ក្នុងចំណោមចម្លើយសាក្សីទាំងនោះ ដែលរួមបញ្ចូលនៅក្នុង**ឧបសម្ព័ន្ធ** I សំដៅដល់ការជម្លៀសប្រជាជនចេញពីបណ្តាទីប្រជុំជន និងភូមិផ្សេងៗទៀតក្រៅពីទីក្រុងភ្នំពេញ រួមមាន បាត់ដំបង កំពង់ឆ្នាំង ប៉ៃលិន ឧត្តុង្គ ពោធិ៍សាត់ និងពីបណ្តាកន្លែងផ្សេងៗទៀតស្ថិតនៅក្នុងខេត្តកំពង់ចាម[9]។ សម្រង់ដែលជាប់ពាក់ព័ន្ធនឹងចម្លើយសាក្សីទាំងនេះ មិនត្រូវបានយកមកបង្ហាញនៅក្នុង**ឧបសម្ព័ន្ធ** II ទេ ប៉ុន្តែឧប្បត្តិហេតុនានាដែលត្រូវបានលើកឡើងនៅក្នុងចម្លើយសាក្សីទាំងនេះ ត្រូវបានរួមបញ្ចូលទៅក្នុងការប្រមូលទិន្នន័យពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនផ្សេងៗទៀត ដែលនឹងត្រូវយោងនៅផ្នែកខាងក្រោយក្នុងសំណើនេះ។

14. ជាការពិតណាស់ ចំនួនចម្លើយសាក្សីដែលមាននៅក្នុង**ឧបសម្ព័ន្ធ** I និងជាតំណាងនៅលើផែនទីនៅក្នុង**ឧបសម្ព័ន្ធ** V មិនបានបង្ហាញពីចំនួនប្រជាជនជាក់ស្តែង ដែលត្រូវបង្ខំឲ្យផ្លាស់ទីនៅក្នុងដំណាក់កាលទី ១ នៃការជម្លៀសប្រជាជននោះទេ។ ចំនួនចម្លើយសាក្សីទាំងនោះ គឺតំណាងឲ្យចំនួនគំរូចម្លើយជ្រើសរើសនៃដំណើររឿងនានារបស់បុគ្គល រៀបរាប់ពីស្ថានការណ៍ផ្សេងៗនៃការជម្លៀស និងទិសដៅរបស់អ្នកត្រូវគេជម្លៀសទាំងឡាយ។ ខណៈដែលចម្លើយសាក្សីមិនបានបង្ហាញពីតួលេខពិតប្រាកដរបស់ប្រជាជនដែលបានផ្លាស់ទី នៅពេលដែលមើលក្នុងទិដ្ឋភាពរួមគ្នា ចម្លើយសាក្សីទាំងនោះបង្កើតបានជាចំណាប់អារម្មណ៍ពីការផ្លាស់ទីក្នុងទ្រង់ទ្រាយធំជាទូទៅមួយ ដោយរួមបញ្ចូលប្រជាជនស៊ីវិលទាំងអស់ (រួមទាំងទាហាន*បាត់បង់សមត្ថភាពប្រយុទ្ធ*) ផងចេញពីទីក្រុងភ្នំពេញ។ របាយការណ៍អ្នកជំនាញផ្នែកប្រជាសាស្ត្រ ដែល ក.ស.ច.ស បានស្នើឲ្យរៀបចំ នៅក្នុងអំឡុងពេលការស៊ើបអង្កេតរបស់តុលាការ ប៉ាន់ស្មានថាតួលេខនេះ គឺទំនងជាមានចំនួនច្រើនបំផុតក្នុងចន្លោះពី១,៥ និង២,៦ លាននាក់[10]។

15. ភ័ស្តុតាងដែលមាននៅក្នុងសម្រង់ចម្លើយសាក្សីនានា គឺមានជាប់ពាក់ព័ន្ធទៅនឹងបទចោទស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជនជាប់ចោទរងការចោទប្រកាន់ នៅក្នុងដំណាក់កាលដំបូងនៃសំណុំរឿង០០២

[9] ឯកសារ D125/171; D125/55; D125/28; D125/92; D232/44; D125/57; D125/177; D125/91; D166/42; D369/9; D166/79; D232/12។

[10] របាយការណ៍អ្នកជំនាញផ្នែកប្រជាសាស្ត្រ រៀបរៀងដោយ បណ្ឌិត Ewa Tabeau និងថី ឃាម ឯកសារ D140/1/1 ទំព័រ ១៩។

ទាក់ទងនឹងដំណាក់កាលទី១នៃការជម្លៀសប្រជាជន។ បទចោទទាំងនេះ រួមមាន ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការវាយប្រហារទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងអំពើអមនុស្សធម៌ផ្សេងទៀត តាមរយៈការផ្លាស់ទីដោយបង្ខំ[11]។ ឧទាហរណ៍ សម្រង់ចម្លើយសាក្សីផ្តល់នូវភ័ស្តុតាងស៊ីសង្វាក់គ្នាដូចជា៖

(ក) ការផ្លាស់ទីស្ថិតក្នុងលក្ខណៈទ្រង់ទ្រាយធំ - ពាក់ព័ន្ធទៅនឹងការបង្កើតធាតុផ្សំទូទៅនៃការវាយប្រហារជាប្រព័ន្ធ ឬរីករាលដាលមួយដោយផ្ទាល់ប្រឆាំងទៅលើប្រជាពលរដ្ឋស៊ីវិល

(ខ) ការផ្លាស់ទីក្នុងលក្ខណៈបង្ខិតបង្ខំ - ពាក់ព័ន្ធទៅនឹងការបង្កើតធាតុផ្សំឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយអំពើអមនុស្សធម៌ផ្សេងៗតាមរយៈការផ្លាស់ទីដោយបង្ខំ

(គ) ស្ថានភាពអមនុស្សធម៌ក្នុងអំឡុងពេលផ្លាស់ទីដោយបង្ខំ និងនៅពេលធ្វើដំណើរទៅដល់ រួមមាន កង្វះម្ហូបអាហារ ទីស្នាក់អាស្រ័យ ការដឹកជញ្ជូន និងការព្យាបាលផ្នែកវេជ្ជសាស្ត្រជាដើម - ពាក់ព័ន្ធទៅនឹងការបង្កើតធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយការសម្លាប់រង្គាល ព្រមទាំងអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការវាយប្រហារទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស

(ឃ) ការរើសអើងទៅលើ "ប្រជាជន ១៧ មេសា" នៅពេលធ្វើដំណើរទៅដល់ទិសដៅថ្មីនានា - ពាក់ព័ន្ធទៅនឹងការបង្កើតធាតុផ្សំទូទៅនៃ "មូលដ្ឋាននៃការរើសអើង" និងធាតុផ្សំផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ព្រមទាំងអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការវាយប្រហារទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស

(ង) លក្ខណៈអចិន្ត្រៃយ៍នៃការជម្លៀសចេញ ដោយជនដែលត្រូវគេជម្លៀស ត្រូវបង្ខំឱ្យរស់នៅតាមបណ្តាទីតាំងថ្មីៗ ព្រមទាំងចូលរួមក្នុងគម្រោងប្រើប្រាស់ពលកម្មដោយបង្ខំនានា - ពាក់

[11] មើលឧបសម្ព័ន្ធភ្ជាប់នឹងសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី, ឯកសារ E124/7.1 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ត្រង់ទំព័រទីពីរ ចំណុចទី៤។

ព័ន្ធទៅនឹងការគ្មានមូលហេតុនានាសម្រាប់ការផ្លាស់ទីប្រជាជន ដែលត្រូវបានអនុញ្ញាតដោយច្បាប់អន្តរជាតិ, និង

(ច) ការកំណត់គោលដៅ និងការសម្លាប់ទៅលើ "ប្រជាជនថ្មី" ព្រមទាំងអតីតទាហាន និងមន្ត្រីរាជការនៃរបប លន់ នល់ ក្នុងអំឡុងពេលផ្លាស់ទី និងនៅពេលធ្វើដំណើរទៅដល់គោលដៅថ្មី - ពាក់ព័ន្ធទៅនឹងការបង្កើតធាតុផ្សំជាទូទៅ នៃ "មូលដ្ឋាននៃការរើសអើង" និងធាតុផ្សំផ្សេងៗទៀត នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយអំពើមនុស្សឃាត និងដោយការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។

16. ពាក់ព័ន្ធនឹងការដាក់គោលដៅ និងការកាប់សម្លាប់ទៅលើ "ប្រជាជនថ្មី" និងអតីតអ្នករដ្ឋការស៊ីវិល និងយោធានៃរបបសាធារណរដ្ឋខ្មែរ គួរកត់សម្គាល់ថា សម្រង់នៃចម្លើយសាក្សីខ្លះ រួមមានភ័ស្តុតាងនៃការកាប់សម្លាប់ដែលបានកើតមាននៅក្នុងស្រុក ១២ និងទួលពោធិ៍ជ្រៃ។ ថ្វីបើនាពេលបច្ចុប្បន្ន ជនជាប់ចោទពុំរងការចោទប្រកាន់ណាមួយពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មទាំងនេះក៏ដោយ[12] ក៏ភ័ស្តុតាងនេះត្រូវបានដាក់បញ្ចូលផងដែរ ដោយហេតុថា ភ័ស្តុតាងនេះពាក់ព័ន្ធសំខាន់ទៅនឹងបញ្ហាទាំងឡាយ នៅក្នុងសំណុំរឿង ០០២។ ភ័ស្តុតាងនេះជួយបញ្ជាក់ថាការផ្លាស់ទីលំនៅដោយបង្ខំ បានកើតមានក្នុងលក្ខណៈជាផ្នែកមួយនៃការវាយប្រហារដោយសារ "មូលហេតុរើសអើង" ដែលជាធាតុផ្សំរួមមួយនៃការចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងអស់។ ភ័ស្តុតាងនេះគាំទ្រដល់ចម្លើយរបស់សាក្សីពាក់ព័ន្ធនឹងការធ្វើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញផ្សេងៗទៅលើ "ប្រជាជនថ្មី" និងអតីតអ្នករដ្ឋការស៊ីវិល និងយោធានៃរបបសាធារណរដ្ឋខ្មែរ ដែលបានកើតមានក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន និងដែលត្រូវបានចោទប្រកាន់មកលើជនជាប់ចោទនៅក្នុងសវនាការនាពេលបច្ចុប្បន្ន[13]។ ភ័ស្តុតាងនេះពាក់ព័ន្ធនឹងការ

[12] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ*នៃវិធានផ្ទៃក្នុង ឯកសារ E124 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១, មើលសេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ឯកសារ E124/7 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១; អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានកម្មវត្ថុថា "សាក្សីដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញក្រុមបន្ទាប់ ដែលអង្គជំនុំជម្រះនឹងស្ដាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១" ឯកសារ E172 ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១២ ទំព័រ ៣ ដល់ទំព័រ ៤។

[13] មើលដីកាដំណោះស្រាយ ត្រង់កថាខណ្ឌ ១៣៧៧ ឯកសារ D427 ដែលបានចោទថា "មនុស្សត្រូវបានសម្លាប់ដោយកងទ័ពខ្មែរក្រហមនៅមុនពេល នៅក្នុងពេល ឬនៅពេលទៅដល់នៃការផ្លាស់ប្ដូរទីលំនៅ ដំណាក់កាលទី ១ និងទី៣" និងកថាខណ្ឌ ១៤១៨ ដែលចោទថា

គ្មានមូលហេតុនានាសម្រាប់ការផ្លាស់ទីលំនៅប្រជាជន ដែលច្បាប់អន្តរជាតិបានអនុញ្ញាត។ ជាចុងក្រោយ ភ័ស្តុតាងនេះពាក់ព័ន្ធនឹងការបញ្ជាក់អំពីអត្ថិភាពនៃគោលបំណងរួម ដើម្បីការពារបក្សកុម្មុយនីស្តកម្ពុជាពីសត្រូវខាងក្រៅ និងសត្រូវផ្ទៃក្នុងតាមរាល់គ្រប់មធ្យោបាយចាំបាច់ រួមទាំងការកំណត់មុខសញ្ញា និងការកាប់សម្លាប់ក្រុមមនុស្សជាក់លាក់ដូចជា អតីតទាហាន និងអ្នករដ្ឋការនៃរបប លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ។

## ខ. ចម្លើយនានាដែលមាននៅក្នុងឧបសម្ព័ន្ធ II

17. **ឧបសម្ព័ន្ធ II** រួមមានសម្រង់ចម្លើយសាក្សីដែលសំដៅដល់ការជម្លៀសដែលបានធ្វើឡើងនៅក្នុងតំបន់រំដោះមុនខែមេសា ឆ្នាំ១៩៧៥ និងនៅតាមទីប្រជុំជន និងស្រុកភូមិផ្សេងទៀតក្រៅពីទីក្រុងភ្នំពេញនៅចំ ឬនៅជិតថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ សម្រង់ទាំងនោះត្រូវបានដកស្រង់ចេញពីចម្លើយសាក្សីចំនួន ៦៤ នាក់។ មានចម្លើយសាក្សីចំនួនបីដែលបញ្ចូលក្នុង**ឧបសម្ព័ន្ធ** II ត្រូវបានដាក់ជូនអង្គជំនុំជម្រះ និងបានចាត់ថ្នាក់នៅក្នុងប្រភេទឯកសារ E3[14]។ ចម្លើយសាក្សីខ្លះក្នុងចំណោមសាក្សីទាំង ៦៤ នាក់ដែលបានបញ្ចូលនៅក្នុង**ឧបសម្ព័ន្ធ** II សំដៅទៅដល់ឧបទ្ទវហេតុនៃការផ្លាស់ទីកន្លែងប្រជាជនដោយបង្ខំដាច់ដោយឡែកពីគ្នា ពោលគឺការជម្លៀសប្រជាជនដែលបានធ្វើឡើងនៅពេលវេលាខុសៗគ្នា ឬនៅតាមទីកន្លែងផ្សេងៗគ្នា។ ជាងនេះទៀត ដូចដែលបានលើកឡើងខាងលើរួចមកហើយ គឺថាចម្លើយចំនួន ១២ ដែលបានបញ្ចូលក្នុង**ឧបសម្ព័ន្ធ** I សំដៅដល់ការជម្លៀសប្រជាជននៅតាមទីប្រជុំជន និងភូមិនានា បន្ថែមទៅលើការជម្លៀសប្រជាជននៅទីក្រុងភ្នំពេញ។ បើរួមបញ្ចូលគ្នាឃើញថា ចម្លើយនានានៅក្នុង **ឧបសម្ព័ន្ធ** I និង II សំដៅដល់ឧបទ្ទវហេតុផ្សេងៗចំនួន ៨៤ នៃការជម្លៀសប្រជាជនចេញពីទីប្រជុំជន និងភូមិនានាដែលបានកើតឡើងមុន និងស្របពេលជាមួយនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។

---

"ក្នុងអំឡុងពេលផ្លាស់ទីលំនៅ ប្រជាជនដែលត្រូវបានចាត់ទុកថាជាខ្មាំងពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានរងការធ្វើបាប និងដាក់ឲ្យរស់នៅក្នុងលក្ខខណ្ឌពិបាកខ្លាំងជាងប្រជាជនផ្សេងៗទៀត"។

[14] ឯកសារ E3/521 (D25/10); E3/403 (D232/27); E3/428 (D234/9) ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួនបីក្នុងចំណោមកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទាំងអស់ ត្រូវបានទទួលយក នៅថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២។ មើលឧបសម្ព័ន្ធ ក ដែលភ្ជាប់នឹងសេចក្តីសម្រេចលើការបដិសេធឯកសារនានាដែលត្រូវបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឯកសារ E185.1 ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២។ ឯកសារ E3/69 ត្រូវបានទទួលយក នៅថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១១។

18. ក្នុងចំណោមឧបទ្ទវហេតុចំនួន ៨៤ ដែលបានពណ៌នានៅក្នុងចម្លើយសាក្សីនេះ ឧបទ្ទវហេតុចំនួន ៨ សំដៅដល់ការជម្លៀសប្រជាជន នៅក្នុងតំបន់រំដោះមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ចំនួនដែលនៅសល់គឺសំដៅដល់ការជម្លៀសប្រជាជនដែលបានធ្វើឡើងនៅចំ ឬនៅជិតថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅតាមទីកន្លែងផ្សេងទៀតនៃប្រទេសកម្ពុជា។ ក្នុងចំណោមឧបទ្ទវហេតុទាំងនេះ ឧបទ្ទវហេតុចំនួន ៦៣ បង្ហាញពីទីប្រជុំជន និងភូមិជាក់លាក់ដែលត្រូវជម្លៀសប្រជាជន។ តារាងខាងក្រោមបង្ហាញពី ខេត្តនានាដែលទីប្រជុំជន និងភូមិទាំងនោះស្ថិតនៅ រួមជាមួយសម្រង់មួយចំនួនដែលបង្ហាញពីការផ្លាស់ទីប្រជាជនចេញពីទីប្រជុំជន ឬភូមិណាមួយនៅក្នុងខេត្តនោះ។ ព័ត៌មានពិស្តារនៃសម្រង់ដែលពាក់ព័ន្ធ ដែលមានលេខឯកសារ និងឈ្មោះសាក្សី ត្រូវបានបញ្ចូលក្នុង**ឧបសម្ព័ន្ធ III** នៃញត្តិនេះ។ ព័ត៌មាននៅក្នុងតារាងខាងក្រោមក៏ត្រូវបានរៀបរាប់នៅក្នុងផែនទីទីពីរក្នុង**ឧបសម្ព័ន្ធ V** ដែរ។ សម្រង់ចំនួន ១៣ ដែលនៅសល់សំដៅដល់ការជម្លៀសប្រជាជនដែលបានធ្វើឡើងនៅចំ ឬនៅជិតថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាលក្ខណៈទូទៅ ដោយមិនបានបង្ហាញច្បាស់នូវឈ្មោះទីប្រជុំជន ឬភូមិដែលមានការជម្លៀសប្រជាជនទេ។

| **ខេត្ត (ជម្លៀសពី ឬក្នុង)** | **ចំនួនសម្រង់** |
|---|---|
| បាត់ដំបង | 10 |
| កំពង់ចាម | 3 |
| កំពង់ឆ្នាំង | 11 |
| កំពង់ស្ពឺ | 2 |
| កំពង់ធំ | 1 |
| កំពត | 4 |
| កណ្ដាល | 2 |
| ប៉ៃលិន | 3 |
| ព្រៃវែង | 2 |
| ពោធិ៍សាត់ | 7 |
| សៀមរាប | 4 |
| ក្រុងព្រះសីហនុ | 9 |

| | |
|---|---|
| ស្វាយរៀង | 4 |
| តាកែវ | 1 |

19. ជាថ្មីម្តងទៀត មានការសង្កត់ធ្ងន់ថា ចំនួនចម្លើយសាក្សីដែលបានបញ្ចូលក្នុង**ឧបសម្ព័ន្ធ** II និងតំណាងនៅលើផែនទីក្នុង**ឧបសម្ព័ន្ធ** V មិនឆ្លុះបញ្ចាំងពីចំនួនប្រជាជនពិតប្រាកដដែលត្រូវបានជម្លៀសដោយបង្ខំមុនពេល ឬស្របពេលទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនោះទេ។ ផ្ទុយទៅវិញ ចំនួនទាំងនេះតំណាងឱ្យគំរូដែលសាក្សីបានលើកឡើង ដែលពិពណ៌នាពីការជម្លៀសប្រជាជនដែលបានកើតឡើងនៅពេលផ្សេងទៀត និងនៅតាមទីកន្លែងផ្សេងទៀតនៃប្រទេសកម្ពុជា ក្រោមការគ្រប់គ្រងរបស់ពួកខ្មែរក្រហម។

20. ទោះបីជនជាប់ចោទមិនត្រូវបានចោទប្រកាន់ទាក់ទិននឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ពីបណ្តាទីប្រជុំជន និងភូមិផ្សេងទៀតដែលបានកើតឡើងមុនពេល ឬស្របពេលទៅនឹងការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញក៏ដោយ ក៏សម្រង់ចម្លើយសាក្សីដែលត្រូវបានបញ្ចូលក្នុង**ឧបសម្ព័ន្ធ** II ពាក់ព័ន្ធនឹងបទចោទប្រឆាំងជនជាប់ចោទ ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែរ។ ដោយឡែកសម្រង់ទាំងនោះផ្តល់ភ័ស្តុតាងស្របគ្នា ពាក់ព័ន្ធនឹងគោលបំណង ការរៀបចំផែនការ និងការអនុវត្តការជម្លៀសប្រជាជន។ ភ័ស្តុតាងនៃការជម្លៀសប្រជាជនដែលបានធ្វើឡើងមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅក្នុងតំបន់រំដោះ និងការជម្លៀសប្រជាជនជាទ្រង់ទ្រាយធំបន្តបន្ទាប់គ្នាចេញពីទីក្រុងនានានៅទូទាំងប្រទេសគឺមានការពាក់ព័ន្ធក្នុងការបង្ហាញពីធាតុផ្សំរួមនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃ "ការវាយប្រហារជាទ្រង់ទ្រាយធំ ឬជាប្រព័ន្ធដោយផ្ទាល់ប្រឆាំងនឹងប្រជាជនស៊ីវិល" ដោយផ្អែកលើ "មូលដ្ឋាននៃការរើសអើង"។ ភ័ស្តុតាងនេះក៏បានបង្ហាញផងដែរថា ពុំមានមូលដ្ឋានផ្សេងទៀតសម្រាប់ការផ្លាស់ប្តូរទីលំនៅដោយបង្ខំដែលត្រូវបានអនុញ្ញាតដោយច្បាប់អន្តរជាតិ សម្រាប់ការផ្លាស់ទីលំនៅដោយបង្ខំនោះទេ និងភ័ស្តុតាងនេះបានគាំទ្រដល់ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាដែលថា ការជម្លៀសប្រជាជនចេញពីទីក្រុងគឺជាផ្នែកមួយនៃគោលនយោបាយនៃសហកម្មឧក្រិដ្ឋកម្មរួម ដែលមេដឹកនាំ ប.ក.ក បានបង្កើតឡើង និងយកមកអនុវត្ត។ លក្ខណៈដែលមានការសម្របសម្រួលត្រឹមត្រូវ និងវិធីសាស្ត្រប្រតិបត្តិការ *(modus operandi)* រួមនៃការជម្លៀសប្រជាជននេះបង្ហាញថា ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញបានធ្វើឡើង ស្របតាមផែនការឧក្រិដ្ឋកម្មរួមដែលត្រូវបានសម្រេចដោយមេដឹកនាំ

ជាន់ខ្ពស់ ប.ក.ក។ ពាក់ព័ន្ធនឹង**ឧបសម្ព័ន្ធ** I វិញ សម្រង់ខ្លះដែលមាននៅក្នុង **ឧបសម្ព័ន្ធ** II បានផ្ដល់ភស្តុតាងអំពីការសម្លាប់មនុស្សនៅស្រុក ១២ និងទួលពោធិ៍ជ្រៃ។ សម្រាប់សំអាងហេតុដែលបានលើកឡើងខាងលើពាក់ព័ន្ធនឹងភស្តុតាងស្រដៀងគ្នា ដែលមានក្នុងសម្រង់ក្នុង**ឧបសម្ព័ន្ធ** I យើងសន្និដ្ឋានថាភស្តុតាងនេះពាក់ព័ន្ធនឹងបទចោទប្រឆាំងនឹងជនជាប់ចោទនៅក្នុងសវនាការនេះដែរ។

## III. ដំណោះស្រាយដែលបានស្នើសុំ

21. ដើម្បីបន្តដំណើរការទៅមុខ សហព្រះរាជអាជ្ញាស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

(ក) ទទួលយកចម្លើយសាក្សីដែលមានក្នុង**ឧបសម្ព័ន្ធ** I និង II ជាភស្តុតាង និងចាត់ថ្នាក់ចម្លើយសាក្សីទាំងនោះជាប្រភេទឯកសារ E3 ទៅតាមវិសាលភាពដែលមិនទាន់បានធ្វើ, និង

(ខ) សំអាងទៅលើសម្រង់ដែលមាននៅក្នុង**ឧបសម្ព័ន្ធ** I និង II ជាភស្តុតាងត្រួតគ្នាក្នុងការរួមបញ្ចូលជាមួយសក្ខីកម្មដោយផ្ទាល់មាត់នៅពេលសវនាការ ក្នុងការកំណត់បទចោទប្រឆាំងនឹងជនជាប់ចោទនៅក្នុងសវនាការដំណាក់កាលដំបូងនៃសំណុំរឿង០០២។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២ | **យ៉េត ចរិយា**<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | [signature] |
| | **William Smith**<br>សហព្រះរាជអាជ្ញារង | | [signature] |